ឯកសារណែនាំពីជំនួយបន្ទាន់

# អ្វីដែលត្រូវធ្វើនៅពេលលោក-អ្នកស្ថិតក្នុង ភាពបន្ទាន់ ឬ បញ្ហា

[ភាសាខ្មែរ]

カンボジア語版

ចងក្រង និង បោះពុម្ពដោយ :
ក្រុមសិក្សាពីគោលនយោបាយអន្តរជាតិរបស់
អាជ្ញាធរក្នុងមូលដ្ឋាន Kanagawa ខែ តុលា ឆ្នាំ ២០០៦

## ព័ត៌មានផ្ទាល់ខ្លួន

ឈ្មោះ : ______________________ ប្រភេទឈាម : ___ Rh ___
អាស័យដ្ឋាន :
ថ្ងៃ-ខែ-ឆ្នាំកំណើត : ______________________
សញ្ជាតិ : ______________________
ភាសាដែលខ្ញុំអាចនិយាយ : ______________________

## ចំណុចទាក់ទងជាមួយគ្រួសាររបស់ខ្ញុំ

ឈ្មោះ : ______________________ ទំនាក់ទំនង : ______________
ទូរស័ព្ទ : ______________ ទូរស័ព្ទដៃ : ______________
អ៊ីម៉េល : ______________________

## កន្លែងធ្វើការរបស់ខ្ញុំ

ឈ្មោះ : ______________________
ទូរស័ព្ទ : ______________________
អ៊ីម៉េល : ______________________

## នៅពេលលោក-អ្នកត្រូវការរថយន្តសង្គ្រោះបន្ទាន់ សម្រាប់ការមានជម្ងឺ ឬ របួសដោយចៃដន្យ:

ទូរស័ព្ទមកកាន់ **1 1 9**.

- នៅពេលដែលលោក-អ្នកធ្លាក់ខ្លួនឈឺ ឬ របួសធ្ងន់ភ្លាម សូមទូរស័ព្ទមកកាន់ស្ថានីយ៍លត់អគ្គីភ័យតាមរយៈលេខ 119 ដើម្បីរករថយន្តសង្គ្រោះបន្ទាន់ ។
- **នៅពេលស្ថានីយ៍អគ្គីភ័យឆ្លើយតប សូមប្រាប់ពួកគេដូចខាងក្រោម :**
  1. វាជាភាពបន្ទាន់ ។
  2. អ្វីដែលបានកើតឡើង (ឧទាហរណ៏ : ស្ថានភាពជម្ងឺ ឬ របួស)
  3. ទីកន្លែងដែលលោក-អ្នកនៅ
  4. ឈ្មោះ និង លេខទូរស័ព្ទរបស់លោក-អ្នក
- ប្រសិនបើលោក-អ្នកមិនអាចនិយាយភាសាជប៉ុន សូមស្នើសុំឱ្យមនុស្សដែលនៅជុំវិញលោក-អ្នកឱ្យធ្វើការទូរស័ព្ទហៅ ។

## ក្នុងករណីមានអគ្គីភ័យ ស្រែកថា "មានអគ្គីភ័យ!" ដើម្បីប្រកាសអាសន្នដល់មនុស្សដទៃ

ទូរស័ព្ទមកកាន់ **1 1 9**.

- **ក្នុងករណីមានអគ្គីភ័យ សូមស្រែកថា "មានអគ្គីភ័យ!" ដើម្បីប្រកាសអាសន្នដល់អ្នកជិត ខាងរបស់លោក-អ្នក**
- ទូរស័ព្ទទៅកាន់ស្ថានីយ៍លត់អគ្គីភ័យតាមរយៈលេខ 119 សម្រាប់ម៉ាស៊ីនលត់អគ្គីភ័យ
- វាជាការគ្រោះថ្នាក់ក្នុងអាគារព្យាយាមលត់អគ្គីភ័យដោយខ្លួនលោក-អ្នកតែឯង ។
- **នៅពេលស្ថានីយ៍លត់អគ្គីភ័យឆ្លើយតប សូមប្រាប់ពួកគេដូចខាងក្រោម :**
  1. មានអគ្គីភ័យ ។
  2. ទីកន្លែងមានអគ្គីភ័យដូចជា អស័យដ្ឋាន ឬ ឈ្មោះអាគារ ។
  3. អ្វីដែលនៅលើអគ្គីភ័យនោះ ។
  4. ចំណុចសំគាល់នៅក្បែរៗនោះដូចជា អាគារជាដើម
  5. ឈ្មោះ និង លេខទូរស័ព្ទរបស់លោក-អ្នក
- ប្រសិនបើលោក-អ្នកមិនអាចនិយាយភាសាជប៉ុន សូមស្នើសុំឱ្យមនុស្សដែលនៅជុំវិញលោក-អ្នកឱ្យធ្វើការទូរស័ព្ទហៅ ។

## ប្រសិនបើលោក-អ្នកបានក្លាយទៅជាជនរងគ្រោះ ពីឧក្រិដ្ឋកម្ម ឬ ពាក់ព័ន្ធនឹងគ្រោះថ្នាក់រថយន្ត :

ទូរស័ព្ទមកកាន់ **1 1 0**.

- ប្រសិនបើលោក-អ្នកត្រូវបានប្លន់ ក្លាយជាជនរងគ្រោះពីអំពើហិង្សា ពាក់ព័ន្ធនឹង គ្រោះថ្នាក់រថយន្ត ឬ ឃើញគ្រោះថ្នាក់/ឧបទ្ទវហេតុណាមួយ សូមទូរស័ព្ទមកប៉ូលីសតាមរយៈ លេខ 110 ។
- **នៅពេលប៉ូលីសឆ្លើយតប សូមប្រាប់ពួកគេដូចខាងក្រោម :**
  1. អ្វីដែលបានកើតឡើង
     (ឧទាហរណ៏ : "ឧបទ្ទវហេតុ/គ្រោះថ្នាក់បានកើតឡើង " ។)
  2. ពេលដែលវាបានកើតឡើង
     (ឧទាហរណ៏ : "គ្រោះថ្នាក់មួយបានកើតឡើងកាលពី ___ នាទី កន្លងមកនេះ")
  3. កន្លែងដែលបានកើតឡើង
     (ឧទារហណ៏ : ទីតាំង ឬ ចំណុចសំគាល់នៅក្បែរៗនោះ ដូចជា អាគារជាដើម)
  4. លក្ខណៈផ្ទៃមុខរបស់ឧក្រិដ្ឋជន សំលៀកបំពាក់ និង ភិនភាគ
  5. ឈ្មោះ និង លេខទូរស័ព្ទរបស់លោក-អ្នក
- ប្រសិនបើលោក-អ្នកមិនអាចនិយាយភាសាជប៉ុន សូមស្នើសុំឱ្យមនុស្សដែលនៅជុំវិញលោក-អ្នកឱ្យធ្វើការទូរស័ព្ទហៅ ។

# ការណែនាំដប់ចំណុចស្តីពីវិធានការណ៍ចំពោះការរញ្ជួយដី

រញ្ជួយដីតែងតែកើតឡើងនៅក្នុងប្រទេសជប៉ុន ។ ក្នុងករណីមានការរញ្ជួយដី សូមធ្វើសកម្មភាព ស្របតាមជំហានខាងក្រោមនេះ ដើម្បីទប់ស្កាត់ការមានរបួស ឬ អគ្គីភ័យ ។

- **កំឡុងពេលមានរញ្ជួយដី**

1. នៅពេលភាពញ័ររញ្ជួយមកដល់ ចូរការពារខ្លួនលោក-អ្នកជាមុនសិន ។ បិទហ្គាស និង ប្រភពនាំឱ្យមានអគ្គីភ័យផ្សេងៗទៀត ។
2. រង់ចាំរហូតដល់ភាពញ័ររញ្ជួយធូរស្រាលទៅវិញ ។
3. បន្តនៅស្ងប់ស្ងៀម និង ធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន ហេតុនេះលោក-អ្នកនឹងមិនធ្វើឱ្យខ្លួនលោក-អ្នករបួសដោយសារវត្ថុដែលបានបែកបាក់ ។
4. បើកបង្អួច ឬ ទ្វារ ដើម្បីឱ្យមានសុវត្ថិភាពដល់ផ្លូវចេញរបស់លោក-អ្នក ។
5. ចូរកុំប្រញាប់ចេញពីផ្ទះរបស់លោក-អ្នក ឬ ចេញពីអាគារ ដោយសារតែអាចមានវត្ថុធ្លាក់មក លើលោក-អ្នក ។
6. នៅឱ្យឆ្ងាយពីរនាំង និង របង ដោយសារតែពួកវាអាចធ្លាក់ចុះមកបាន

- **បន្ទាប់ពីការរញ្ជួយដី**

7. ប្រមូលព័ត៌មានត្រឹមត្រូវតាមវិទ្យុ ឬ ទូរទស្សន៍ និង ធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន
8. ធ្វើឱ្យច្បាស់ថាមានសុវត្ថិភាពចំពោះគ្រួសារ និង អ្នកជិតខាងរបស់លោក-អ្នក ។
9. សហការជាមួយមនុស្សផ្សេងទៀតក្នុងអាគារសង្គ្រោះ និង ការព្យាបាលបឋម
10. មុនពេលជម្លៀសខ្លួនចេញ សូមមើលឱ្យច្បាស់ថាបានបិទប្រដាប់បិទភ្លើង និង ហ្គាស ។

## កន្លែងជម្លៀសខ្លួនចេញរបស់គ្រួសារខ្ញុំ ( កន្លែងជួបជុំគ្នា)

**ឈ្មោះកន្លែង :**

**អាស័យដ្ឋាន :**

**ទូរស័ព្ទ :**

- ដើម្បីប្រុងប្រៀបចំពោះភាពបន្ទាន់ សូមពិភាក្សា និង ធ្វើផែនការជាមួយគ្រួសាររបស់លោក-អ្នកពីវិធីសាស្ត្រទំនាក់ទំនង កន្លែងជួបជុំគ្នា និង ផ្លូវសុវត្ថិភាពទៅកាន់កន្លែងជម្លៀស ខ្លួន ។

បញ្ជីរាយឧបករណ៍សង្គ្រោះបន្ទាន់

**[វត្ថុដែលត្រូវយកចេញ]**

**ចូររៀបចំវត្ថុដូចខាងក្រោម ហើយដាក់វានៅក្នុងកាបូបស្ពាយ ។ល។ ក្នុងករណីមានការជម្លៀស**

ទឹក វិទ្យុ សំលៀកបំពាក់ ស្បែកជើង អាហារ ឈើគូស ឬ ដែកកេះ វត្ថុមានតម្លៃ ពិល គ្រឿងសង្គ្រោះបឋម ឧបករណ៍សរសេរ អាវភ្លៀង សំលៀកបំពាក់សម្រាប់អាកាសធាតុត្រជាក់ ក្រដាសអនាម័យ និង វត្ថុផ្សេងៗទៀតដែលសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃ

**[ការស្តុកទុកសម្រាប់ភាពអាសន្ន]**

**ចូររៀបចំដូចខាងក្រោមដើម្បីរួចជីវិតបានសម្រាប់រយៈពេលប្រហែលជា 3 ថ្ងៃបន្ទាប់ពីការរញ្ជួយដី**

ឡើន ចង្ក្រានហ្គាសដែលអាចដាក់តាមខ្លួនបាន ប្រេងរំអិល ទឹកផឹក ( ក្នុងធុងជ័រ ។ល។ ប្រហែល ជា 3 លីត្រ ក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់) និង ចំណីអាហារ

## ដើម្បីទំនាក់ទំនងសមាជិកគ្រួសាររបស់លោក-អ្នក

- **ហៅតាមសារបន្ទាន់ពីមហន្តរាយ NTT អាចទទួលបាន ។**

| ដើម្បីថតសារ | | ដើម្បីស្តាប់សារ |
|---|---|---|
| 171 | | 171 |
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |
| 1 | | 2 |
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |

លេខទូរស័ព្ទ ( លើត) របស់មនុស្សដែលស្ថិតក្នុងតំបន់ដែលរងប្រហារដោយគ្រោះមហន្តរាយ : (xxx)-xxx-xxxx

| | | |
|---|---|---|
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |
| 1 # | | 1 # |
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |
| ចេញពីសាររបស់លោក-អ្នក ( រយៈពេល 30 វិនាទី) | | ស្តាប់សារ |
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |
| 9 # | | 9 # |
| ↓ | ( ការណែនាំជាភាសាជប៉ុន) | ↓ |
| | ចប | |

- ក្រុមហ៊ុនទូរស័ព្ទដៃក៏អាចផ្តល់ជូននូវសេវាកម្មផ្ញើសារពីគ្រោះមហន្តរាយរបស់ពួកគេក្នុងករណីមានភាពបន្ទាន់ផងដែរ ។

## សេវាកម្មផ្តល់ប្រឹក្សា

ភាសាជាច្រើនដែលអាចមានសម្រាប់ការផ្តល់សេវាកម្មនេះ មានភាពខុសគ្នាតាមទីកន្លែង និង តាម ថ្ងៃនៃសប្តាហ៍ ។ សូមទូរស័ព្ទទាក់ទងដើម្បីទទួលព័ត៌មានលំអិត ។

- **សេវាកម្មថ្នាក់ខេត្ត**

បើកពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង 9:00 ដល់ម៉ោង 12:00 និង 13:00 ដល់ 16:00

មជ្ឈមណ្ឌល Kanagawa Kenmin Center ____ 045 (410) 3131

មជ្ឈមណ្ឌល Ken-o Region Prefectural Administration Center ____ 046 (223) 0709

មជ្ឈមណ្ឌល Kawasaki Kenmin Center ____ 044 (549) 0047

- **សេវាកម្មបកប្រែភាសាពេទ្យ**

សំណើសុំសេវាកម្មនេះ ទទួលយកពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង 9:00 ដល់ម៉ោង 12:00 និង ពីម៉ោង 13:00 ដល់ម៉ោង 16:00 ។

MIC Kanagawa ____ 045 (317) 8803

- **សេវាកម្មផ្តល់ប្រឹក្សារបស់សាលាក្រុង**

សមាគម Yokohama Association for International Communication and Exchange ____ 045 (222) 1209

សមាគម Kawasaki International Association ____ 044 (435) 7000

សមាគម Yokosuka International Association ____ 046 (827) 2166

ការិយាល័យក្រុង Hiratsuka ____ 0463 (21) 8764

ការិយាល័យក្រុង Fujisawa ____ 0466 (25) 1111

សាលាក្រុង Chigasaki (ណាត់ជួបជាចាំបាច់) ____ 0467 (82) 1111

ការិយាល័យក្រុង Atsugi ____ 046 (225) 2100

សមាគម Yamato International Association ____ 046 (260) 5126

សាលាក្រុង Sagamihara ____ 042 (769) 8319

ការិយាល័យក្រុង Hadano ____ 0463 (82) 2001

ការិយាល័យក្រុង Yugawara ____ 0465 (63) 2111

ការិយាល័យក្រុង Aikawa ____ 046 (285) 2111